# សេចក្តីថ្លែងការណ៍រួម
# "ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាគន្លឹះសំខាន់ក្នុងការលើកកម្ពស់សុចរិតភាព និងតម្លាភាពនៅកម្ពុជា"

អង្គការសង្គមស៊ីវិលកម្ពុជាដែលមានឈ្មោះខាងក្រោម សូមស្នើឱ្យរាជរដ្ឋាភិបាល និងស្ថាប័នសភាជាតិ អនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឱ្យបានឆាប់ ស្របតាមបទដ្ឋានអន្តរជាតិ និងធានាបាននូវសិទ្ធិសេរីភាពក្នុងការទទួលព័ត៌មានក្នុងយុគសម័យឌីជីថលលើគ្រប់វិស័យ ជាពិសេសសិទ្ធិទទួលព័ត៌មាន លើការគ្រប់គ្រងហិរញ្ញវត្ថុនិងលទ្ធកម្មសាធារណៈ។

បន្ទាប់ពីអស់រយៈពេលជិត២ទសវត្សរ៍ ដែលសេចក្តីព្រាងច្បាប់ដ៏សំខាន់នេះបានចាប់ផ្តើមតាក់តែងឡើង ប្រជាជនកម្ពុជានៅតែមានកង្វល់អំពីសិទ្ធិរបស់ខ្លួនក្នុងការទទួលព័ត៌មានសាធារណៈនៅឡើយ ដោយសារតែអាជ្ញាធរទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមានភាពស្ទាក់ស្ទើរក្នុងការបើកចំហ ឬផ្សព្វផ្សាយព័ត៌មានមួយចំនួន ព្រមទាំងកង្វះធនធាន និងសមត្ថភាពមានកម្រិត បើទោះបីជាគោលការណ៍ជាតិនិងអន្តរជាតិអំពាវនាវឱ្យរដ្ឋបាលសាធារណៈយកចិត្តទុកដាក់ក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការបើកចំហព័ត៌មានក៏ដោយ។

នៅក្នុងប្រទេសជឿនលឿន ជាពិសេសប្រទេសដែលប្រាថ្នាចង់ក្លាយខ្លួនជាប្រទេសអភិវឌ្ឍន៍ ដែលមានចំណូលមធ្យម និងកម្រិតខ្ពស់ ព័ត៌មានសាធារណៈគឺជាគន្លឹះមួយនៃភាពជោគជ័យ។ សាធារណជនត្រូវការព័ត៌មានសាធារណៈ ដើម្បីតាមដានការងាររបស់តំណាងរបស់ខ្លួននៅគ្រប់កម្រិត។ ប្រសិនបើមិនមានតម្លាភាព និងការទទួលបានឯកសារថវិកា លទ្ធកម្មសាធារណៈ និងទិន្នន័យហិរញ្ញវត្ថុដែលរឹងមាំទេ វាជាចន្លោះប្រហោងយ៉ាងធំ និងពិបាកក្នុងការប្រឆាំងអំពើពុករលួយ។ ហេតុដូចនេះ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាច្បាប់មួយសំខាន់ក្នុងការចូលរួមដោយផ្ទាល់ប្រឆាំងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាពក្នុងសង្គម។

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានបើកចំហទិន្នន័យទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ថ្នាក់ជាតិមួយចំនួន ដែលនេះជាការចូលរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាននៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការផ្តល់ និងទទួលព័ត៌មានសាធារណៈផ្សេងៗទៀតនៅមានកម្រិតនៅឡើយ ដែលប៉ះពាល់ជាយថាហេតុដល់សិទ្ធិ និងផលប្រយោជន៍នានារបស់ប្រជាពលរដ្ឋ ជាពិសេសលើព័ត៌មានសំខាន់ៗដូចជាព័ត៌មានលទ្ធកម្មសាធារណៈ និងព័ត៌មានថវិកាចំណូលចំណាយស្ថាប័នសាធារណៈ ដែលពាក់ព័ន្ធនឹងដំណើរការអភិវឌ្ឍន៍ប្រទេស និងដោយផ្ទាល់លើសិទ្ធិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋជាច្រើន។

ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល និងយុវជនទទួលស្គាល់ការខិតខំប្រឹងប្រែងមួយចំនួនរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន ជាពិសេសនៅថ្នាក់ក្រោមជាតិតាម រយៈ

កម្មវិធីមួយចំនួនដូចជា គម្រោងគណនេយ្យភាពសង្គម ការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និង ការិយាល័យច្រកចេញចូលតែមួយជាដើម។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចាប់ផ្តើមដំណើរការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ទទួលបានការកោតសរសើរពីក្រុមការងារអង្គការសង្គមស៊ីវិល។ ក្នុងជំនួបជាមួយអ្នកសារព័ត៌មានក្នុងស្រុកលើកទី៥ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានលើកឡើងថា ច្បាប់ស្តីពីការទទួលព័ត៌មាននឹងអនុម័តក្នុងឆ្នាំ២០២៤ ឬយ៉ាងយូរឆ្នាំ២០២៥ ក្នុងអាណត្តិសភាលើកទី៧។

ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិសិទ្ធិទទួលព័ត៌មានជាសកលឆ្នាំ២០២៦ ក្រោមប្រធានបទ "ការធានានូវសុចរិតភាពនៃព័ត៌មាន និងតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា" ក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល សូមស្នើជូន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាល និងសភាកម្ពុជា** នូវចំណុចដូចខាងក្រោម៖

- ពន្លឿនការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលស្របតាមបទដ្ឋានអន្តរជាតិក្នុងឆ្នាំ២០២៦ ឬឆ្នាំ២០២៧។
- សូមបញ្ជាក់ឱ្យបានច្បាស់ និងលម្អិត អំពីព័ត៌មានណាខ្លះជាប្រភេទព័ត៌មានសម្ងាត់ក្នុងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។
- ណែនាំក្រសួង មន្ទីរ និងអង្គភាពនានារបស់រដ្ឋ បើកចំហព័ត៌មានសាធារណៈឱ្យបានទូលំទូលាយ ជាពិសេស ព័ត៌មានថវិកាចំណូលចំណាយស្ថាប័នសាធារណៈ និងព័ត៌មានលទ្ធកម្មសាធារណៈ។
- ពង្រឹង និងបង្កើតនូវយន្តការទាំងឡាយ ជាពិសេសយកចិត្តទុកដាក់លើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ រួមទាំងប្រព័ន្ធឌីជីថល ដើម្បីធានាថា ប្រជាពលរដ្ឋ ក្រុមយុវជន ជនមានពិការភាព និងជនជាតិដើមភាគតិច ទទួលបានព័ត៌មានពេញលេញ។
- ផ្តល់កិច្ចការពារចំពោះប្រជាពលរដ្ឋគ្រប់រូបដែលបានបង្ហាញ និងចែកចាយនូវព័ត៌មានពិតប្រាកដ ឬព័ត៌មានទាំងឡាយណាដែលបម្រើដល់ប្រយោជន៍សាធារណៈ។
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសិទ្ធិទទួលព័ត៌មាន និងលើកទឹកចិត្តប្រជាពលរដ្ឋ ជាពិសេស យុវជនឱ្យចូលរួមក្នុងការស្វែងរកព័ត៌មានសាធារណៈទាំងឡាយ ដែលពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ។
- បង្កើតឱ្យមានបរិយាកាសកាន់តែប្រសើរឡើង សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេស យុវជនក្នុងដំណើរការកសាងផែនការ និងថវិកា លទ្ធកម្មសាធារណៈនៅគ្រប់កម្រិត។

**ថ្ងៃចន្ទ ២រោច ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០**
**រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៦**

ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក **ឡាំ សុជាតិ** នាយកប្រតិបត្តិ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
តំណាងអង្គការសង្គមស៊ីវិលធ្វើការលើកកម្ពស់សិទ្ធិទទួលព័ត៌មាន (A2IWG)
ទូរសព្ទ៖ ០១២ ៧១៨ ៦១១

**អង្គការសមាជិកក្រុមការងារសិទ្ធិទទួលព័ត៌មាន៖**

1. អង្គការ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) និងជាលេខាធិករដ្ឋានក្រុមការងារសិទ្ធិទទួលព័ត៌មាននៃអង្គការសង្គមស៊ីវិល(A2IWG)
2. អង្គការ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC)
3. អង្គការ ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
4. អង្គការ សមាគមនសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
5. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
6. អង្គការ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
7. អង្គការជនពិការកម្ពុជា (CDPO)
8. អង្គការ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
9. អង្គការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (CMPO)
10. អង្គការ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
11. អង្គការ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRAC)
12. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
13. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum)
14. អង្គការ មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP Center)
15. អង្គការ ស្តារកម្ពុជា (Star Kampuchea)
16. អង្គការ តម្លាភាពកម្ពុជា (TIC)
17. អង្គការ ក្រុមទ្រទ្រង់ភូមិ (VSG)
18. អង្គការ មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)
19. អង្គការ ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)
20. អង្គការ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
21. បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្តក្រចេះ
22. បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្តពោធិ៍សាត់
23. បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្តសៀមរាប
24. បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្តស្វាយរៀង

**អង្គការសង្គមស៊ីវិល ចូលរួមគាំទ្រសេចក្តីថ្លែងការណ៍រួម៖**

25. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (សម្ព័ន្ធភាព CPDD)
26. អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD)
27. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
28. អង្គការបណ្តុះគំនិត (COO)
29. អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា (SVC)
30. អង្គការអប់រំ អភិវឌ្ឍន៍ សហគមន៍ជនបទ (ECD)
31. អង្គការអនុផលព្រៃឈើ (NTFP)
32. អង្គការនាគព័ន្ធដើម្បីអភិវឌ្ឍន៍ (NOD)
33. អង្គការរចនាស្ត្រី (RS)
34. អង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO)
35. សមាគមសំឡេងស្ត្រីសហគមន៍ (WCV)
36. អង្គការកាត់បន្ថយទុពលភាព និងអនក្ខរភាព ( VIR )
37. អង្គការជនពិការខេត្តក្រចេះ (KDPO)
38. អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ (NAS)
39. អង្គការគោលដៅយើង (OOO)
40. អង្គការពន្លឺកុមារ (PK)
41. សមាគមអភិវឌ្ឍន៍ស្រីកម្ពុជា (CWDA)
42. អង្គការទឹកដីសុវណ្ណភូមិ (TDSP)
43. អង្គការអភិវឌ្ឍន៍កុមារ និងសហគមន៍ (CCDO)
44. អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា(CCSP)
45. អង្គការអនាគតកុមារ(AK) Anakot Kumar
46. អង្គការខ្មែរអភិវឌ្ឍន៍ជនពិការ និងក្រីក្រ(CADDP)
47. សមាគម ផ្ទះទឹកដូង (PTDA)
48. អង្គការថ្នាលទំពាំង(HBO)
49. អង្គការវេទិកាស្ត្រីពិការខេត្តបាត់ដំបង (BWWDF)
50. អង្គការអភិវឌ្ឍន៍ដើម្បីកុមារកម្ពុជា (DCC)
51. សហភាពសហគមន៍កសិកម្មសហគ្រិនអភិវឌ្ឍន៍សង្គម (SEUAC)
52. អង្គការពន្លកខ្មែរ (PKH)
53. សមាគមភ្នំនាងកង្រី (PNKA)
54. អង្គការអប់រំ សុខភាព និងបរិស្ថាន (EHE)
55. អង្គការខេមរា (Khemara)

56. អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍ (CCD)
57. អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO)
58. អង្គការសហគមន៍អភិវឌ្ឍន៍មិត្តជនបទ (RFCD)
59. អង្គការសាលាភាសាបរទេសជុំគ្រៀល (CLS)
60. អង្គការសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ (COFAP)
61. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD)
62. អង្គការសាមគ្គី (Samaky)
63. អង្គការកម្មវិធីជួយកុមារអនាថានិងអភិវឌ្ឍន៍ (SCADP)
64. អង្គការអភិវឌ្ឍន៍ស្ត្រី (AS)
65. អង្គការសង្គ្រោះជនទុរគត និងមនុស្សចាស់ (HOM)
66. មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ (MPC)
67. មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា(CWDCC)
68. អង្គការព្រហ្មវិហារធម៌(PVT)
69. អង្គការព្រែកទាល់ឈានឆ្ពោះទៅមុខ PTMA)
70. អង្គការខ្មែរជំនាន់ថ្មី (KNGO)
71. អង្គការមណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា(OCCO)
72. អង្គការអភិវឌ្ឍន៍សំឡេងសហគមន៍ BCV
73. បណ្ដាញអង្គការមិនមែនរដ្ឋាភិបាលខេត្តកំពង់ឆ្នាំង
74. សហគមន៍អ្នកផ្ទុកមង្គលបូរី ខេត្តបន្ទាយមានជ័យ
75. សហគមន៍ស្រនាល ខេត្តបន្ទាយមានជ័យ
76. សហគមន៍នេសាទរុងរឿង ខេត្តបន្ទាយមានជ័យ
77. ក្រុម យុវជនរួបរួមសាម្មីដើម្បីអភិវឌ្ឍន៍សហគមន៍ ស្រះរាំង ខេត្តបន្ទាយមានជ័យ
78. អភិវឌ្ឍន៍មូលដ្ឋានយុវជន ខេត្តបន្ទាយមានជ័យ
79. ក្រុមយុវជនសកម្មបម្រើសង្គមឃុំសំបួរ ខេត្តបន្ទាយមានជ័យ
80. យុវជនសម្រាប់អភិវឌ្ឍន៍សហគមន៍ ខេត្តបន្ទាយមានជ័យ
81. សហគមន៍ភ្នៀតកោះពងសត្វ ខេត្តបន្ទាយមានជ័យ
82. សហគមន៍ កសិកម្មភ្នៀតមានជ័យ ខេត្តបន្ទាយមានជ័យ
83. ចលនាយុវជនស្ម័គ្រចិត្ត ខេត្តបន្ទាយមានជ័យ
84. សហគមន៍ព្រៃឈើប្រាំបីមុម ស្រុកថ្លង ខេត្តកំពង់ស្ពឺ
85. សហគមន៍អមលាំង ស្រុកថ្លង ខេត្តកំពង់ស្ពឺ
86. សហគមន៍ព្រៃឈើទ័ពមាន ស្រុកថ្លង ខេត្តកំពង់ស្ពឺ
87. សហគមន៍កសិកម្មរុងរឿង ស្រុកថ្លង ខេត្តកំពង់ស្ពឺ

88. សហគមន៍សាមគ្គីអភិរក្សបឹងចាងបឹងប្រាំង( កំពងធំ )
89. សហមន៍តំបន់ការពារធម្មជាតិជាំឆ្លក( កំពងធំ )
90. សហគមន៍តំបន់ការពារធម្មជាតិស្អរក្រូច( កំពងធំ )
91. សហគមន៍ព្រៃឈើក្បាលខ្លា( កំពងធំ )
92. សហគមន៍ព្រៃឈើក្បាលអូរធ្នុង( កំពងធំ )
93. សហគមន៍កន្សែងវា( កំពងធំ )
94. សហគមន៍សាលាឆ្ពោ( កំពងធំ )
95. សហគមន៍ព្រៃឈើជាំម្រេច( កំពងធំ )
96. សហគមន៍ជនជាតិដើមភាគតិចគួយ ( ខេត្តក្រចេះ )
97. សហគមន៏ប្រាសាទខ្វាន់ពីរ( ខេត្តក្រចេះ )
98. សហគមន៏ព្រៃឈើប្បៀរ( ខេត្តក្រចេះ )
99. សហគមន៍ព្រៃឈើអូរជីកជ័យមហា ខេត្តពោធិ៏សាត់
100. សហគមន៍ព្រឈើចំបក់ផ្អែម ខេត្តពោធិ៏សាត់
101. សហគមន៍ព្រៃឈើអូរបាក់ត្រា ខេត្តពោធិ៏សាត់
102. សហគមន៍ព្រៃឈើដៃគូសំរោង ខេត្តពោធិ៏សាត់
103. សហគមន៍កសិកម្មសំរោងសែនជ័យ ខេត្តពោធិ៏សាត់
104. សហគមន៍ព្រៃឈើគល់ទទឹង ខេត្តពោធិ៏សាត់
105. សហគមន៍ព្រៃឈើអូរថ្កូវ ខេត្តពោធិ៏សាត់
106. សហគមន៍កសិកម្មដប់បាតអភិវឌ្ឍ ខេត្តពោធិ៏សាត់
107. សហគមន៍ព្រៃឈើរតនៈឡបាក់ ខេត្តពោធិ៏សាត់